### កម្ពុជាចាំបាច់ត្រូវមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន គឺជាច្បាប់មួយដែលធានាសិទ្ធិប្រជាពលរដ្ឋខ្មែរ ដើម្បីទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ។

### តើរាជរដ្ឋាភិបាលកម្ពុជាបានធ្វើអ្វីខ្លះដែលទាក់ទងនឹងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន?

នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨ ខែមីនា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានសន្យាថា នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ ស្តីពីសិទ្ធិទទួលព័ត៌មានឱ្យហើយនៅខែធ្នូ ឆ្នាំ២០០៦។ បច្ចុប្បន្ននេះ សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយត្រូវបានតាក់តែងដោយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច ដើម្បីដាក់ជូនរដ្ឋាភិបាលសម្រេច។ ក្របខ័ណ្ឌគោលនយោបាយនេះ គឺជាមូលដ្ឋានសម្រាប់ធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។

ប្រជាពលរដ្ឋខ្មែរ សូមអំពាវនាវយ៉ាងទទូចឱ្យរាជរដ្ឋាភិបាលកម្ពុជាអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន នៅឆ្នាំ ២០០៨។

### តើចំណុចអ្វីខ្លះត្រូវដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន?

ផ្អែកលើការប្រតិបត្តិល្អពីប្រទេសនានាលើសកលលោក ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបញ្ចូលគោលការណ៍ ដូចតទៅ:

១. **ការបើកចំហជាអតិបរមា:** គឺរដ្ឋនានាគប្បីបញ្ចូលគោលការណ៍បើកចំហព័ត៌មានជាអតិបរមា។

២. **កាតព្វកិច្ចផ្សព្វផ្សាយដល់សាធារណជន:** ស្ថាប័នសាធារណៈ គប្បីមានកាតព្វកិច្ចផ្សព្វផ្សាយដល់សាធារណជន នូវព័ត៌មានសំខាន់ៗ។

៣. **ការលើកស្ទួយរដ្ឋាភិបាលឱ្យមានលក្ខណៈបើកចំហ:** ស្ថាប័នសាធារណៈ ត្រូវតែចូលរួមលើកស្ទួយឱ្យសកម្ម ដើម្បីមានរដ្ឋាភិបាលមួយ ដែលមានលក្ខណៈបើកចំហ។

៤. **ដែនកំណត់នៃការលើកលែង:** ការលើកលែងទាំងឡាយ គប្បីកំណត់ន័យឱ្យបានច្បាស់ និងក្នុងក្របខ័ណ្ឌជាក់លាក់ ជាពិសេសត្រូវមានការថ្លឹងថ្លែងឱ្យបានសមរម្យពីផលប្រយោជន៍សាធារណៈ និងភាពគ្រោះថ្នាក់។ ការថ្លឹងថ្លែងគប្បីមានចែងក្នុងច្បាប់ ហើយគួរការពារផលប្រយោជន៍សាធារណៈ។

៥. **ដំណើរការសម្របសម្រួលសិទ្ធិទទួលព័ត៌មាន:** សំណើសុំព័ត៌មានគប្បីឆ្លើយតបឱ្យបានឆាប់រហ័ស និងយុត្តិធម៌។ រយៈពេលឆ្លើយតប ត្រូវកម្រិតពេលវេលាច្បាស់លាស់។ ករណីបដិសេធមិនផ្តល់ព័ត៌មាន ត្រូវបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ ហើយគប្បីមាន យន្តការពិនិត្យមើលដោយឯករាជ្យលើករណីនេះផង។

៦. **ការបង់ថ្លៃព័ត៌មាន:** ថ្លៃសុំព័ត៌មានមិនត្រូវថ្លៃហួសហេតុ ដែលធ្វើឱ្យអ្នកសុំព័ត៌មានរួញរាមិនហ៊ានសុំ។ ក្នុងករណីផ្តល់ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានដែលជាផលប្រយោជន៍សាធារណៈ ត្រូវតែឥតបង់ថ្លៃ។

៧. **កិច្ចប្រជុំបើកចំហ:** កិច្ចប្រជុំរបស់ស្ថាប័នសាធារណៈ គប្បីបើកចំហសម្រាប់សាធារណជន។

៨. **ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវតែមានអាទិភាព:** ច្បាប់ទាំងឡាយណា ដែលមិនស្របទៅនឹងគោលការណ៍បើកចំហជាអតិបរមា នៃច្បាប់នេះគប្បីកែប្រែ ធ្វើវិសោធនកម្ម ឬលុបចោល។

៩. **ការការពារប្រភពព័ត៌មាន:** បុគ្គលដែលបានបញ្ចេញព័ត៌មាន ស្តីពីការប្រព្រឹត្តខុស ឬលាតត្រដាងព័ត៌មានណាមួយ ដោយសារតែការគិតគូរផ្អែកលើប្រយោជន៍សាធារណៈ ត្រូវតែទទួលបានការការពារពីច្បាប់នេះ។

ឧបត្ថម្ភដោយ:

USAID FROM THE AMERICAN PEOPLE

British Embassy Phnom Penh

ផលិតដោយ:

BUILDING CAPACITY WORLDWIDE Pact Cambodia

FOI DISCLOSE PUBLIC INFORMATION

# សិទ្ធិទទួលព័ត៌មាន



## សិទ្ធិដឹងគឺជាសិទ្ធិដើម្បីរស់

## ប្រជាពលរដ្ឋខ្មែរមានសិទ្ធិដឹង

## តើអ្វីជាព័ត៌មានសាធារណៈ?

ព័ត៌មានសាធារណៈ គឺជាព័ត៌មានទាំងឡាយ ដែលប្រមូល ចងក្រង និងកាន់កាប់ដោយស្ថាប័នសាធារណៈ ហើយស្ថិតនៅក្រោម បញ្ញត្តិច្បាប់ ឬទាក់ទងនឹងកិច្ចការផ្លូវការទាំងឡាយរបស់ស្ថាប័នសាធារណៈ។ ព័ត៌មានសាធារណៈ អាចមានទម្រង់ជា សៀវភៅ ក្រដាសស្នាម លិខិត ឯកសារ រូបថត ភាពយន្ត ខ្សែអាត់មីក្រូហ្វីស មីក្រូហ្វីល សម្លេងអាត់ទុក ផែនទី និងគំនូរ ខ្សែវីដេអូ សម្លេង រូបភាព ឬទិន្នន័យសម្លេង និងវីដេអូ។

## ប្រជាពលរដ្ឋខ្មែរមានសិទ្ធិដឹង

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិដឹងអំពីកិច្ចការសាធារណៈ ឬព័ត៌មានសាធារណៈ ពីព្រោះពួកគាត់ជាអ្នកបង់ពន្ធ និងជាម្ចាស់ប្រទេសជាតិរបស់ខ្លួន។ សិទ្ធិទាំងនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣១:** *ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាព្រមទាំងសន្ធិសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ...។*

**មាត្រា៣៥:** *ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាព នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។*

**មាត្រា៤១:** *ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ...។*

សិទ្ធិជាមូលដ្ឋានទាំងនេះ ធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋ ដើម្បីទទួលបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនូវព័ត៌មានប្រកបដោយគុណភាពខ្ពស់ និងត្រឹមត្រូវដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរសាធារណៈផ្សេងទៀត។ សិទ្ធិទាំងនេះត្រូវបានធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលកម្ពុជាបានផ្តល់សច្ចាប័ន នៅឆ្នាំ ១៩៩២ :

**មាត្រា ១៩ :**

១- *ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក។*

២- *ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវបានរាប់បញ្ចូល ទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន ។*

## តើសិទ្ធិទទួលព័ត៌មានជួយកាត់បន្ថយអំពើពុករលួយដូចម្តេច?

សិទ្ធិទទួលព័ត៌មានមាន គឺជាឧបករណ៍ដ៏សំខាន់មួយដែលធានាការបើកចំហ និងតម្លាភាព សម្រាប់លើកស្ទួយអភិបាលកិច្ចល្អ និងកាត់បន្ថយអំពើពុករលួយ។

## តើអ្វីជាសិទ្ធិទទួលជាព័ត៌មាន ?

គឺជាសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបាននូវព័ត៌មាន ពីស្ថាប័នសាធារណៈទាំងឡាយ ហើយសិទ្ធិនោះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់។

ឧទាហរណ៏:

- ប្រជាពលរដ្ឋម្នាក់ មានសិទ្ធិទទួលបានព័ត៌មានពីក្រុមប្រឹក្សាឃុំ ទាក់ទងនឹងការដេញថ្លៃ និងការចំណាយផ្សេងៗរបស់ឃុំដែលគាត់រស់នៅ។
- អ្នកកាសែតម្នាក់ មានសិទ្ធិទទួលបានព័ត៌មានពីមន្ត្រីសាធារណៈនៃក្រសួងណាមួយ ដែលទាក់ទងទៅនឹងការដេញថ្លៃ និងការចំណាយផ្សេងៗរបស់ក្រសួងនោះ។

## តើសិទ្ធិក្នុងការទទួលព័ត៌មានផ្តល់ប្រយោជន៏អ្វីខ្លះដល់យើង?

### *សម្រាប់ប្រជាពលរដ្ឋ*

- អាចដឹងថា តើសេវាសាធារណៈណាខ្លះដែលមិនបង់ថ្លៃ ហើយបើបង់ថ្លៃ តើពួកគេត្រូវចំណាយប្រាក់ប៉ុន្មាន?
- អាចតាមដានសំណើសុំនានាដែលបានស្នើសុំទៅអាជ្ញាធរដូចជា: ការធ្វើអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត និងលិខិតស្នាមផ្សេងៗថា តើដំណើរការដល់ណាហើយ?
- អាចដឹងពីការចំណាយរបស់ស្ថាប័នសាធារណៈ សម្រាប់គម្រោងការអ្វីមួយ ។ល។

### *សម្រាប់សមាជិកសភា មន្ត្រីរដ្ឋាភិបាល និងតុលាការ*

- អាចឱ្យសមាជិកសភា ទទួលបានព័ត៌មានជាក់លាក់ស្តីពីកិច្ចការសាធារណៈ ពីស្ថាប័នសាធារណៈដូចជាគម្រោងអភិវឌ្ឍ កិច្ចសន្យាសាធារណៈជាមួយក្រុមហ៊ុនឯកជន ការចំណាយរបស់ស្ថាប័នសាធារណៈជាដើម
- អាចឱ្យមន្ត្រីរដ្ឋាភិបាលទទួលបានព័ត៌មានពីស្ថាប័នសាធារណៈផ្សេងៗបានរហ័សទាន់ចិត្ត ជាអាទិ៍ដូចជាសវនករជាតិ អាចទទួលព័ត៌មានស្តីពីការចំណាយរបស់ក្រសួងនានាជាដើម
- អាចឱ្យមន្ត្រីតុលាការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈពេលត្រូវការ ដើម្បីការងារស៊ើបអង្កេត ។ល។

### *សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ*

- អាចស្នើសុំទៅស្ថាប័នសាធារណៈ ហើយអាចទទួលបានព័ត៌មានផ្លូវការសម្រាប់ការងារផ្សព្វផ្សាយរបស់ខ្លួន
- មន្ត្រីសាធារណៈលែងមានលេសលាក់ព័ត៌មានសាធារណៈ ដែលធ្វើឱ្យការផ្សព្វផ្សាយកាន់តែមានលក្ខណៈវិជ្ជាជីវៈ ។ល។

### *សម្រាប់វិស័យឯកជន*

- អាចទទួលបានព័ត៌មានផ្លូវការស្តីពីការដេញថ្លៃគម្រោងសាធារណៈ ក៏ដូចជាគម្រោងអភិវឌ្ឍនានារបស់រដ្ឋ
- អាចទទួលបានព័ត៌មានផ្លូវការ ស្តីពីស្ថានភាពសេដ្ឋកិច្ច វិនិយោគ ពន្ធដារ ច្បាប់ ទម្លាប់ និងព័ត៌មានដទៃទៀតដែលមានប្រយោជន៏សម្រាប់កិច្ចការអាជីវកម្ម ។ល។

### *សម្រាប់សង្គមស៊ីវិល*

- អាចទទួលបានព័ត៌មានផ្លូវការទាក់ទងនឹងកិច្ចការសាធារណៈពីស្ថាប័នសាធារណៈផ្សេងៗ ដើម្បីចូលរួមផ្តល់យោបល់ធ្វើកិច្ចសហប្រតិបត្តិការក្នុងនាមដៃគូអភិវឌ្ឍ ។ល។